# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## តំណាងរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុង
## ពិធីបិទសន្និបាតបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ ២០២១
## និង លើកទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ ២០២២
## រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០២១ (តាមប្រព័ន្ធវីដេអូ)

- *ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម;*
- *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក, សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!*

ជាថ្មីម្តងទៀត, ខ្ញុំពិតជាមានកិត្តិយស និង ក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុត ពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ធ្វើជាអធិបតី ក្នុង ពិធីបិទសន្និបាតបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ ២០២១ និង លើកទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ ២០២២ របស់ក្រសួងពាណិជ្ជកម្ម ។ ក្នុងឱកាសដ៏ប្រពៃនេះ, ខ្ញុំសូមពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និង ក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ពី **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជូនដល់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃក្រសួង

ពាណិជ្ជកម្ម និង ការក្រើនរំលឹកឱ្យមន្ត្រីទាំងអស់ បន្តខិតខំអនុវត្តនូវវិធានការ «៣-ការពារ និង ៣-កុំ» សំដៅចៀសឱ្យផុតពីការរាតត្បាតនៃជំងឺកូវីដ-១៩ ។

ជាការពិត, ក្នុងបរិការណ៍ដែលសភាពការណ៍តំបន់ និង សកលលោក មានការវិវត្តយ៉ាងឆាប់រហ័ស ពិបាកប៉ាន់ប្រមាណបាន, ការពិនិត្យ និង ការវាយតម្លៃលទ្ធផលការងារ ដែលសម្រេចបានក្នុងឆ្នាំកន្លងទៅ ព្រមទាំងការលើកទិសដៅការងារច្បាស់លាស់ទាក់ទងនឹងវិស័យពាណិជ្ជកម្ម សម្រាប់ឆ្នាំ ២០២២ និង រយៈពេលមធ្យមខាងមុខ គឺជាការងារដ៏ចាំបាច់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា, ជាពិសេស សម្រាប់ក្រសួងពាណិជ្ជកម្ម, ដើម្បីអាចឆ្លើយតបបានប្រកបដោយប្រសិទ្ធភាព ទៅនឹងការប្រែប្រួលនៅក្នុងនិម្មាបនកម្មសេដ្ឋកិច្ច និង ភូមិសាស្ត្រនយោបាយ, ទាំងក្នុងកម្រិតតំបន់ និង កម្រិតសកល, នេះម្យ៉ាង; និង ម្យ៉ាងទៀត, ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា, ជាពិសេស នៅក្នុងបរិការណ៍នៃការរស់នៅជាមួយជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សំដៅស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចជាតិ ឱ្យស្ទុះងើបឡើងវិញ ប្រកបដោយចីរភាព, បរិយាបន្ន និង ភាពធន់ ។

### *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ក្នុងឆ្នាំ ២០២១ នេះ, ទោះបីជាជំងឺកូវីដ-១៩ បន្តឆ្លងរាលដាលនៅគ្រប់ប្រទេស និង បង្កភាពមិនប្រាកដប្រជាខ្ពស់ តាមរយៈការបំប្លែងខ្លួនជាប្រភេទវីរុសកូវីដ-១៩ ថ្មីៗក៏ដោយ, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត, ភាពឈ្លាសវៃ និង ភាពបុរេសកម្ម របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាលកម្ពុជា អាចគ្រប់គ្រងសភាពការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេស បានល្អប្រសើរ, ធៀបនឹងប្រទេសនានា ក្នុងតំបន់ និង លើសកលលោក, ពិសេស តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវយុទ្ធសាស្ត្រចាក់វ៉ាក់សាំង, វិធានការសុខាភិបាល, វិធានការអប់រំ និង វិធានការច្បាប់ផ្សេងៗទៀតជាច្រើន ដែលមានភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ។ ការណ៍នេះបានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការទប់ស្កាត់ និង ការកាត់បន្ថយការឆ្លង ព្រមទាំងក្នុងការការពារសុខុមាលភាព និង អាយុជីវិតរបស់ប្រជាជន ។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានដាក់ចេញ និង ជំរុញអនុវត្តនូវកញ្ចប់វិធានការអន្តរាគមន៍ ចំនួន ១០ ជុំ ជាបន្តបន្ទាប់ ក្នុងគោលបំណងទ្រទ្រង់ និង ស្តារសកម្មភាពអាជីវកម្ម និង ធុរកិច្ចឱ្យងើបឡើងវិញ និង ជួយទំនុកបម្រុងដល់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និង ងាយរងគ្រោះ ។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានប្រើប្រាស់ថវិកាប្រមាណ ៨២៩ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២០ សម្រាប់អន្តរាគមន៍, ទាំងផ្នែកសុខាភិបាល, សង្គម និង សេដ្ឋកិច្ច, ហើយទំហំថវិកានេះ បានកើនឡើងរហូតដល់ទៅប្រមាណ ១.៤៥៤ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២១ ។ សម្រាប់ឆ្នាំ ២០២២, រាជរដ្ឋាភិបាលគ្រោងបន្តបញ្ចេញថវិកាអន្តរាគមន៍បន្ថែមទៀត ក្នុងទំហំប្រមាណ ១.០១៤ លានដុល្លារអាម៉េរិក ។ គិតជារួម, សម្រាប់រយៈពេល ៣ ឆ្នាំ (២០២០-២០២២), ធនធានថវិកាដែលយើងបញ្ចេញ គឺមានទំហំរហូតដល់ទៅប្រមាណ ៣.៤០០ លានដុល្លារអាម៉េរិក ។ ជាលទ្ធផល, កម្ពុជាអាចរក្សាបានល្អជាទូទៅនូវលំនឹងជីវភាពប្រជាជន ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាពិសេស គឺគ្រប់គ្រងបានជារួម នូវអតិផរណា និង ស្ថិរភាពនៃអត្រាប្តូរប្រាក់ ។

ឈរលើមូលដ្ឋាននៃសមិទ្ធផលដែលសម្រេចបានក្នុងឆ្នាំនេះ ជាពិសេស ការសម្រេចបាននូវអត្រាការចាក់វ៉ាក់សាំងខ្ពស់ដែលបង្កើតបាននូវ «**ភាពស៊ាំសហគមន៍**» ដ៏រឹងមាំ; ការបិទបញ្ចប់នូវ «**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១**» ក៏ដូចជាការបើកប្រទេស និង ការបើកសកម្មភាពសង្គម-សេដ្ឋកិច្ចក្នុងស្រុកពេញលេញឡើងវិញ; និង ការបន្តកើនឡើងនូវតម្រូវការខាងក្រៅ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានធ្វើការវាយតម្លៃឡើងវិញកាលពីពេលថ្មីៗនេះថា កំណើនសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ ២០២១ នឹងអាចសម្រេចបាន ក្នុងអត្រាប្រមាណ ៣% ដែលប្រសើរជាងរំពឹងទុក ក្នុងអត្រាប្រមាណ ២,៤% នៅក្នុងការវាយតម្លៃពីពាក់កណ្តាលឆ្នាំ ។ ផ្អែកលើទិន្នន័យ ១១ ខែ នៃឆ្នាំ ២០២១, ការនាំចេញ (មិនរាប់បញ្ចូលការនាំចេញមាស) មានកំណើនរឹងមាំ ក្នុងអត្រា ២២,៦% បើប្រៀបធៀបនឹង -៣,២% សម្រាប់រយៈពេលដូចគ្នា នៃឆ្នាំ ២០២០ ខណៈដែលការនាំចូលទំនិញរបស់កម្ពុជា (មិនរាប់បញ្ចូលការនាំចូលមាស) បានកើនឡើង ២៥,៣% ធៀបនឹង -១១,២% ។

ជាមួយនឹងវឌ្ឍនភាព និង និន្នាការជាវិជ្ជមានទាំងនេះ, កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងរយៈពេលមធ្យម ត្រូវបានព្យាករថា នឹងបន្តងើបឡើងវិញលឿន ដែលគាំទ្រដោយការរំពឹងទុកនៃការកើនឡើងតម្រូវការសកល និង ទំនុកចិត្តរបស់វិនិយោគិនបរទេស ដោយសារការគ្រប់គ្រងបានល្អនូវស្ថានភាពនៃការរីករាលដាលជំងឺកូវីដ-១៩, ជាពិសេស ការដាក់ឱ្យអនុវត្តនូវ «ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣» ដែលនឹងពង្រឹងឡើងវិញនូវចន្ទល់សេដ្ឋកិច្ចកម្ពុជាដែលរងផលប៉ះពាល់អវិជ្ជមានពីវិបត្តិជំងឺកូវីដ-១៩ ព្រមទាំងអភិវឌ្ឍបន្ថែមនូវចន្ទល់សេដ្ឋកិច្ចថ្មីប្រកបដោយសក្តានុពល ដើម្បីពន្លឿនការស្តារ និង ការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ឱ្យវិលត្រលប់ទៅស្ថិតនៅលើវិថីនៃកំណើនជាសក្តានុពលរបស់ខ្លួនវិញ ។

### *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ខ្ញុំបានស្តាប់ដោយយកចិត្តទុកដាក់ នូវសេចក្តីរាយការណ៍របស់ **ឯកឧត្តម រដ្ឋមន្ត្រី ប៉ាន សូរស័ក្តិ** ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងារដ៏ល្អ ដែលសម្រេចបានមក នៅក្នុងបរិបទដ៏លំបាកនៃវិបត្តិជំងឺកូវីដ-១៩ និង ភាពមិនប្រាកដប្រជាខ្ពស់នៃការប្រែប្រួលនៅក្នុងពាណិជ្ជកម្មសកល ។ ខ្ញុំសូមគូសរំលេចឡើងវិញនូវសមិទ្ធផលគន្លឹះគួរជាទីមោទនៈមួយចំនួន ដែលក្រសួងពាណិជ្ជកម្មសម្រេចបាន នៅក្នុងឆ្នាំ ២០២១ នេះ រួមមាន ៖ (១). ការសម្រេចបាននូវ **កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន** និង **កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប)** ដែលនឹងចូលជាធរមាននៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២២ ខាងមុខ; (២). ការចុះហត្ថលេខាលើ **កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង**; (៣). ការចុះហត្ថលេខាទ្វេភាគីលើ **អនុស្សរណៈស្តីពីការធ្វើពាណិជ្ជកម្មអង្ករ**; (៤). ការពង្រឹងសមត្ថភាពផលិតករ, ការធ្វើកំណែទម្រង់ស៊ីជម្រៅ និង ការកែលម្អការផ្តល់សេវាសាធារណៈរបស់ក្រសួង ជូនដល់ធុរជន និង សាធារណជនទូទៅ; (៥). ការកសាងលិខិតបទដ្ឋាននៃច្បាប់ពាណិជ្ជកម្ម; (៦). ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ និង សុខុមាលភាពរបស់ប្រជាជន; (៧). ការលើកកម្ពស់ការងារសម្រួលពាណិជ្ជកម្ម; (៨). ការចូលរួមចំណែករក្សាបាននូវ

សន្តិសុខស្បៀង; និង (៩). ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង បានល្អ ។ល។ ក្នុងនាម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមសម្តែងនូវការ-កោតសរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម រដ្ឋមន្ត្រី ប៉ាន សូរស័ក្តិ** និង ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងពាណិជ្ជកម្ម ដែលបានរួមគ្នាអស់ពីកម្លាំងកាយ-ចិត្ត និង ប្រាជ្ញា-ស្មារតី ក្នុងការបំពេញភារកិច្ច ប្រកបដោយសាមគ្គី-ភាព និង ការទទួលខុសត្រូវខ្ពស់ នាំឱ្យសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន ដូចដែលខ្ញុំបានរៀបរាប់ជាយ៉ៗខាងលើនេះ សម្រាប់ជាឧត្តមប្រយោជន៍ជូនជាតិ និង ប្រជាជន ។

ទោះជាយ៉ាងនេះក៏ដោយ, នៅក្នុងបរិការណ៍ថ្មីដែលពោរពេញទៅដោយបញ្ហាប្រឈម និង ភាពមិនប្រាកដប្រជាខ្ពស់នេះ, ស្របតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** អំពី ការប្រែក្លាយការគំរាមកំហែងនានា ជាពិសេស វិបត្តិជំងឺកូវីដ-១៩ ឱ្យទៅជាឱកាសសម្រាប់ការកែទម្រង់នៅក្នុងប្រទេស និង សម្រាប់ការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងការបន្តធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និង សកល-លោក, ក្រសួងពាណិជ្ជកម្មត្រូវបន្តអនុវត្តការងារ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការបង្កើនភាពប្រកួតប្រជែងពាណិជ្ជកម្មកម្ពុជា តាមរយៈ : (១). ការបន្តចរចាបើកច្រកទីផ្សារសំដៅទាញយកផលប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា; (២). ការ-បន្តកសាងច្បាប់ និង ការពង្រឹងសមត្ថភាពមន្ត្រី; (៣). ការលុបបំបាត់ឧបសគ្គនៃការធ្វើពាណិជ្ជកម្ម និង ធុរកិច្ច ដើម្បីរួមចំណែកបង្កបរិយាកាសអំណោយផលដល់ធុរកិច្ច និង ការវិនិ-យោគ, (៤). ការបន្តចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់ នូវវិធានការកែទម្រង់ស៊ី-ជម្រៅដ៏មុតស្រួចទាំងឡាយ របស់រាជរដ្ឋាភិបាល, និង (៥). ការចូលរួមពង្រឹងសមត្ថភាពផលិតរបស់សហគ្រាសធុនតូច និង មធ្យម និង សមត្ថភាពអ្នកផ្តល់សេវាពាណិជ្ជកម្ម ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនៃសហគ្រាសកម្ពុជា ក្នុងការដណ្តើមយកទីផ្សារ និង ការធ្វើសមាហរណ-កម្មខ្លួន ចូលក្នុងខ្សែប្រវាក់ផលិតកម្មតំបន់ និង សកល ។

លើមូលដ្ឋាននៃទស្សនៈ និង តម្រូវការចាំបាច់ ដូចបានគូសរំលេចខាងលើនេះ, ដើម្បីជាវិភាគទានបន្ថែមដល់ការកំណត់ទិសដៅការងារពាណិជ្ជកម្មឆ្នាំ ២០២២, ខ្ញុំស្នើសូមឱ្យក្រសួងពាណិជ្ជកម្មផ្តោតការយកចិត្តទុកដាក់លើការងារជាក់ស្តែងមួយចំនួន ដូចខាងក្រោម ៖

ទី១- **បន្តពង្រឹងការកែទម្រង់ផ្ទៃក្នុង** ដោយប្រកាន់ខ្ជាប់នូវ **អភិក្រមទាំង ៥** របស់ប្រមុខនៃរាជរដ្ឋាភិបាល គឺ : **ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់** សំដៅពង្រឹងក្រម-សីលធម៌ស្អាតស្អំ និង អភិបាលកិច្ចល្អ ក្នុងការបំពេញការងារ និង តួនាទី ប្រកបដោយវិជ្ជាជីវៈ និង មានប្រសិទ្ធភាពខ្ពស់ ។

ទី២- **បន្តរក្សា និង ជំរុញកំណើននៃការនាំចេញ** តាមរយៈការរក្សាទីផ្សារចាស់ និង ការ-ពង្រីកទីផ្សារថ្មី ដោយខិតខំទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀងអាស៊ាន និង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និង កម្ពុជា-កូរ៉េ ឱ្យបានជាអតិបរិមា តាមរយៈការសហការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំ និង ការជំរុញអនុវត្តយុទ្ធសាស្ត្រ និង វិធានការគោលនយោបាយចាំបាច់នានា ឱ្យបានគ្រប់ជ្រុងជ្រោយ និង មានប្រសិទ្ធភាពខ្ពស់ ។

ទី៣- **លើកកម្ពស់ការសិក្សា និង ការវិភាគបែបវិទ្យាសាស្ត្រ** ឱ្យបានច្បាស់លាស់, ជាពិសេស ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់ រួមទាំង វិស័យឯកជនផង, មុននឹងចាប់ផ្តើមការចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា រួមមាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និង ដៃគូសំខាន់ៗ ជាអាទិ៍ រវាង កម្ពុជា-ឥណ្ឌា, កម្ពុជា-ជប៉ុន, កម្ពុជា-រុស្ស៊ី, កម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ាអាស៊ី (EAEU), កម្ពុជា-កាណាដា ជាដើម ។

ទី៤- **ពង្រឹងការពិនិត្យឱ្យបានល្អិតល្អន់ អំពីផលប៉ះពាល់នៃការចរចា ក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO)** ជាពិសេស កិច្ចព្រមព្រៀងស្តីពីការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចនឹងបង្កផលប៉ះពាល់ក្នុងរយៈពេលវែងមកលើកម្ពុជា រួមបញ្ចូលនូវផលប៉ះពាល់លើផ្នែកពន្ធ, ផ្នែកកម្មសិទ្ធិបញ្ញា, និង ផ្នែកការពារទីផ្សារសេវាក្នុងស្រុកជាដើម ។

ទី៥- បន្តសហការជាមួយនឹងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីលើកសំណើគោរពសុំការសម្រេចដ៏ខ្ពង់ខ្ពស់ ពីសំណាក់ **សម្តេច**

**តេជោ នាយករដ្ឋមន្ត្រី** លើការរៀបចំបង្កើតគណៈកម្មាធិការជាតិចរចាពាណិជ្ជកម្ម ដែលមានលក្ខណៈអចិន្ត្រៃយ៍ សម្រាប់សិក្សា, រៀបចំផែនការ និង យុទ្ធសាស្ត្រចរចា, និង ដឹកនាំការចរចាជាមួយនឹងដៃគូពាក់ព័ន្ធ លើការចូលរួមរបស់កម្ពុជានៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ។

**ទី៦- លើកកម្ពស់កិច្ចសហការជាមួយអង្គការអន្តរជាតិ ដែលមានចរិតឯករាជ្យផ្នែកវិជ្ជាជីវៈ** ដើម្បីសិក្សាពីកាលបរិច្ឆេទ និង លទ្ធភាពនៃការចាកចេញរបស់កម្ពុជា ពីឋានៈជាប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) ។ ក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំយុទ្ធសាស្ត្រចាកចេញពី LDC របស់កម្ពុជា សំដៅធានាឱ្យការចាកចេញនេះប្រកបដោយភាពរឹងមាំ និង មានភាពធន់នឹងឥទ្ធិពលពីកត្តាខាងក្រៅ ជាពិសេស **ត្រូវត្រៀមខ្លួនក្នុងការចរចា** សុំភាពអនុគ្រោះថ្មី (GSP Plus) សំដៅរក្សាទីផ្សារ និង លំនឹងផលិតកម្ម ព្រមទាំងភាពទាក់ទាញសម្រាប់ការវិនិយោគនៅកម្ពុជា ។ ទន្ទឹមនេះ, ក្រសួងពាណិជ្ជកម្ម ក៏ត្រូវសិក្សាផងដែរ អំពីផលប៉ះពាល់ពីការបាត់បង់ទីផ្សារ (Preferences eroded) ដោយការប្រកួតប្រជែងនៃបណ្តាប្រទេសមួយចំនួន ដែលបានបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយដៃគូពាណិជ្ជកម្មរបស់កម្ពុជា ។

**ទី៧- សម្របសម្រួលពិនិត្យ និង រៀបចំគោលនយោបាយពាណិជ្ជកម្មថ្មី ជាមួយប្រទេសជិតខាង ដែលកម្ពុជាមានឱនភាពជញ្ជីងពាណិជ្ជកម្មធំ** ដោយត្រូវរៀបចំគោលនយោបាយជាកញ្ចប់ សំដៅជំរុញលើកកម្ពស់ការប្រើប្រាស់ផលិតផលក្នុងស្រុកជំនួសផលិតផលនាំចូលផង និង ដោះស្រាយបញ្ហាប្រឈមរបស់ផលិតករក្នុងស្រុកផង រួមមានដូចជា ការបញ្ចុះថ្លៃដើម និង ការដឹកជញ្ជូន, ការពង្រឹងផលិតភាព និង ម៉ាកយីហោផលិតផល, ការបង្កើតថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់លក់ទំនិញដល់ទីផ្សារ, ការណែនាំឱ្យមានកិច្ចសន្យាផលិត និង ផ្គត់ផ្គង់, ការដោះស្រាយឧបសគ្គផ្នែកអនាម័យ និង ភូតគាមអនាម័យ, និង ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាដើម ។

**ទី៨- បង្កើនភាពប្រកួតប្រជែង និង លើកកម្ពស់គុណភាពសេវាសាធារណៈ** តាមរយៈការបង្កើនកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេស ក្រសួងកសិកម្ម រុក្ខាប្រមាញ់

និង នេសាទ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ក្នុងការរៀបចំ និង ការដាក់ចេញនូវគោលនយោបាយ និង វិធានការសម្រួលធុរកិច្ចចាំបាច់នានា រួមមាន ការ-ជំរុញនូវការតភ្ជាប់ប្រព័ន្ធផ្តល់សេវាតាមថ្នាលបច្ចេកវិទ្យាផ្លាស់ប្តូរទិន្នន័យរួម (CamDX) និង ការចូលរួមដោយសកម្មក្នុងការអនុវត្តគម្រោងបញ្ចរតែមួយជាតិ ជាដើម ។

ទី៩- ជំរុញការផ្សព្វផ្សាយ និង ការអនុវត្តច្បាប់សំខាន់ៗ រួមមាន ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់, ច្បាប់ស្តីពីការប្រកួតប្រជែង ព្រមទាំងច្បាប់ និង យុទ្ធសាស្ត្រស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅចាប់យកកាលានុវត្តភាពពីការវិវត្តយ៉ាងលឿននៃសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ និង សកលលោក ។

ទី១០- ចូលរួមអនុវត្ត ក្នុងឆន្ទៈមុតស្រួច និង ភាពជាម្ចាស់ នូវ "ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣" ដែលរាជរដ្ឋាភិបាលទើបប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ក្នុងពេលថ្មីៗកន្លងទៅ ដើម្បីជាវិភាគទានដល់ការប្រឹងប្រែងរួមគ្នាសំដៅលើកកម្ពស់កិច្ចអភិវឌ្ឍជាតិ និង លើកស្ទួយជីវភាពរបស់ប្រជាជន ។

ទី១១- ខិតខំសម្របសម្រួលជាមួយបណ្តាក្រសួង និង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងលេខា-ធិការដ្ឋានអាស៊ាន និង បណ្តាប្រទេសជាសមាជិក ដើម្បីរៀបចំ និងដឹកនាំកិច្ចប្រជុំរបស់អាស៊ាន ក៏ដូចជាកិច្ចប្រជុំរវាងអាស៊ានជាមួយដៃគូពាក់ព័ន្ធ នៅក្រោមសសរស្តម្ភសេដ្ឋកិច្ច ឱ្យបានល្អប្រសើរ ដើម្បីជានាភាគជោគជ័យរបស់កម្ពុជា ក្នុងឋានៈជាប្រធានអាស៊ាន នៅក្នុងឆ្នាំ ២០២២ ខាងមុខនេះ ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

មុននឹងបញ្ចប់, ខ្ញុំសូមលើកទឹកចិត្តថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងពាណិជ្ជកម្ម បន្តខិតខំអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីសម្រេចឱ្យបានជោគជ័យលើគ្រប់ការងារដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួង ស្របតាមគោលដៅកំណត់ ។ ជាថ្មីម្តងទៀត, ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ ជូនចំពោះឯកឧត្តមរដ្ឋមន្ត្រី, ឯក-

ឧត្តម, លោកជំទាវ, លោក, លោកស្រី, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និង វិស័យឯកជន, ភ្ញៀវជាតិ និង អន្តរជាតិ ព្រមទាំងមន្ត្រីរាជការគ្រប់លំដាក់ថ្នាក់ ដែលបានចូលរួមចំណែកយ៉ាងសកម្ម នៅក្នុងការជំរុញវិស័យពាណិជ្ជកម្មកម្ពុជា ឱ្យមានសម្ទុះរីកចម្រើនយ៉ាងឆាប់រហ័ស ។

នៅចុងបញ្ចប់, ខ្ញុំសូមប្រសិទ្ធពរជ័យ ជូន **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, ឯកឧត្តម, លោកជំទាវ, ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ របស់ក្រសួងពាណិជ្ជកម្ម ក៏ដូចជាសមាជិក-សមាជិកាទាំងអស់នៃអង្គសន្និបាត បានប្រកបនឹងសុខភាពល្អបរិបូរ និង សម្រេចជោគជ័យក្នុងគ្រប់ភារកិច្ច, ពិសេស ចៀសផុតពីជំងឺកូវីដ-១៩ ។

ក្នុងនាម សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាស បិទសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ ២០២១ និង លើកទិសដៅការងារពាណិជ្ជកម្ម ឆ្នាំ ២០២២ នាពេលនេះ ។

***សូមអរគុណ!***